ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 13-Nov-2014, 16:00
CMS/CFO: Sann Rada

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

# គោលជំហររបស់លោក ខៀវ សំផន បន្ទាប់ពីសេចក្តីសម្រេច
# របស់អង្គជំនុំជម្រះសាលាដំបូង E320/1

---

ដាក់ដោយ៖

**មេធាវីការពារក្តីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

ដាក់ជូន៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

ចៅក្រម Claudia FENZ

ចៅក្រម យ៉ា សុខន

**ជំនួយការ៖**
លោកស្រី សេង សុជាតា
កញ្ញា Marie CAPOTORTO
កញ្ញា Soumeya MEDJEBEUR
លោក Pierre TOUCHE
កញ្ញា អ៊ួច ស្រីផាត់
លោក Clément BOSSIS

**សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**មេធាវីការពារក្តីលោក នួន ជា**

# គោលជំហរនៅមុខអង្គជំនុំជម្រះសាលាដំបូង

## **<u>វិធានីតិវិធី</u>**

១. តាមរយៈសេចក្ដីសម្រេច ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បានបដិសេធសំណើរបស់លោក ខៀវ សំផន សុំឲ្យពន្យារពេលចាប់ផ្ដើមសវនាការលើសំណុំរឿង ០០២/០២ រហូតដល់ពេលអង្គជំនុំជម្រះតុលាការកំពូល ("តុលាការកំពូល") ចេញសាលដីកាស្ដាពរ ឬជាជម្រើសមួយទៀត សុំប្ដឹងជំទាស់ចិត្តចៅក្រម[1]។ នៅថ្ងៃដដែលនោះ អង្គជំនុំជម្រះបានចេញដីកាកំណត់កាលបរិច្ឆេទចាប់ផ្ដើមសវនាការលើអង្គសេចក្ដី វគ្គដំបូង ក្នុងសំណុំរឿង ០០២/០២ ពីថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ដល់ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ ("ដីកាកំណត់កាលបរិច្ឆេទ")[2]។

២. តាមរយៈសំណើថ្មី ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១៤ លោក ខៀវ សំផន បានសុំឲ្យពិចារណាឡើងវិញលើដីកាកំណត់កាលបរិច្ឆេទ និងសុំពន្យារពេលសវនាការលើសំណុំរឿង ០០២/០២ ទៅក្រោយពេលចេញសេចក្ដីសម្រេចលើបណ្ដឹងជំទាស់ចិត្ត ហើយទោះជាយ៉ាងណាក៏ដោយ គឺនៅក្រោយពេលដាក់សារណាបណ្ដឹងសាទុក្ខ។ តាមរយៈសេចក្ដីសម្រេច ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ អង្គជំនុំជម្រះបានបដិសេធសំណើនេះ[3]។

៣. ក្នុងអំឡុងសវនាការធ្វើសេចក្ដីសន្និដ្ឋានចោទប្រកាន់ កាលពីថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ លោក ខៀវ សំផន បានបញ្ជាក់ជូនអង្គជំនុំជម្រះដំបូងថា ការបើកសវនាការលើសំណុំរឿង ០០២/០២ ក្នុងពេលដំណាលគ្នាជាមួយនឹងការតាក់តែងសារណាបណ្ដឹងសាទុក្ខ មិនអាចឲ្យគាត់ និងមេធាវី

---

[1] សេចក្ដីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពន្យារការចាប់ផ្ដើមសំណុំរឿង ០០២/០២ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **E314/5**។

[2] ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្ដី ក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **E316.1** និងឧបសម្ព័ន្ធ **E316.1** ("ដីកាកំណត់កាលបរិច្ឆេទ")។

[3] សេចក្ដីសម្រេចលើសំណើជាបន្ទាន់របស់ ខៀវ សំផន សុំឲ្យពិចារណាឡើងវិញលើដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **E314/5/3**។

ការពារក្តីរបស់គាត់ ផ្តង់អារម្មណ៍លើសារណាបណ្តឹងសាទុក្ខបានទេ។ ដោយសារតែការចំណាយពេលលើសារណាបណ្តឹងសាទុក្ខ មានសារៈសំខាន់ជាងការចំណាយពេលលើសវនាការក្នុងសំណុំរឿង ០០២/០២ លោក ខៀវ សំផន បានពន្យល់ថា គាត់ត្រូវបង្ខំចិត្តផ្តល់អាទិភាពលើនីតិវិធី ដែលកាលកំណត់ និងបញ្ហាប្រឈម មានសារៈសំខាន់ជាង ក្នុងដំណាក់កាលនេះនៃការជំនុំជម្រះក្តីលើរូបគាត់[4]។ ជាក់ស្តែង ដោយហេតុថាអង្គជំនុំជម្រះដែលត្រូវជំនុំជម្រះសំណុំរឿង ០០២/០២ មានសមាសភាពចៅក្រមដដែល ដែលបានប្រកាសសាលក្រមលើសំណុំរឿង ០០២/០១ លោក ខៀវ សំផន ត្រូវផ្តោតអារម្មណ៍លើការធ្វើយ៉ាងណាឱ្យតុលាការកំពូលបដិសេធទឡ្ហីករណ៍លើអង្គហេតុ និងអង្គច្បាប់របស់អង្គជំនុំជម្រះ ដែលឈានទៅដល់ការផ្តន្ទាទោសដាក់ពន្ធនាគាររូបលោកអស់មួយជីវិត។

៤. លោក ខៀវ សំផន បានបង្ហាញឆន្ទៈសុខចិត្តនៅមន្ទីរឃុំឃាំង ដើម្បីធ្វើការលើសារណាបណ្តឹងសាទុក្ខ ដូចដែលគាត់បាន និងកំពុងធ្វើ តាំងពីពេលប្រកាសការផ្តន្ទាទោសលើរូបគាត់មក។ ក៏ប៉ុន្តែ ដោយសារគាត់ដឹងថាគាត់មិនអាចប្រឆាំងនឹងការបង្ខំឱ្យមកបង្ហាញខ្លួនក្នុងសវនាការបាន គាត់បានបង្គាប់ឱ្យមេធាវីរបស់គាត់ប្រើប្រាស់ពេលវេលា និងមធ្យោបាយទាំងអស់ ទៅលើបណ្តឹងសាទុក្ខរហូតដល់ពេលបញ្ចប់ការតាក់តែងសារណាជាភាសាបារាំង។

៥. មេធាវីការពារក្តីលោក ខៀវ សំផន ធ្លាប់បានបញ្ជាក់រួចមកហើយថា ជម្រើសដ៏លំបាកនេះ គឺដើម្បីការពារផលប្រយោជន៍របស់ជនជាប់ចោទឱ្យបានប្រសើរបំផុត។ មេធាវីការពារក្តីបានជម្រាបជូនអង្គជំនុំជម្រះថា ខ្លួននឹងគោរពតាមការបង្គាប់របស់លោក ខៀវ សំផន ដោយចំណាយពេលវេលាទាំងអស់ ដែលបានផ្តល់ឱ្យក្នុងក្របខ័ណ្ឌនៃការការពារក្តីលោក ខៀវ សំផន សម្រាប់ការតាក់តែងសារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤[5]។

៦. នៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានរៀបចំកិច្ចប្រជុំរៀបចំសវនាការ

---

[4] ប្រតិចារឹកសវនាការ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **E1/242.1** ទំព័រ ៥៣ ដល់ទំព័រ ៥៦ ចន្លោះម៉ោង [14.04.10] ដល់ [14.18.24]។

[5] ប្រតិចារឹកសវនាការ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **E1/242.1** ទំព័រ ៥៦ ដល់ទំព័រ ៦១ ចន្លោះម៉ោង [14.18.24] ដល់ [14.38.12]។

ដែលមានរបៀបវារៈពាក់ព័ន្ធនឹងតែការជំនុំជម្រះក្តីលើសំណុំរឿង ០០២/០២។ មេធាវីការពារក្តីមិនបានចូលរួមនោះទេ ដោយសារតែជាប់រវល់នឹងការតាក់តែងសារណាបណ្តឹងសាទុក្ខ។ បន្ទាប់ពីកិច្ចប្រជុំនោះ អង្គជំនុំជម្រះបានព្រមានដល់មេធាវីការពារក្តីទាំងពីរក្រុម និងបានកោះហៅភាគីឲ្យចូលរួមកិច្ចប្រជុំរៀបចំសវនាការថ្មីមួយទៀត នៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤។ នៅក្នុងកិច្ចប្រជុំនោះ លោក ខៀវ សំផន និងមេធាវីរបស់គាត់ បានពន្យល់ជាថ្មីម្តងទៀតអំពីគោលជំហររបស់ខ្លួនក្នុងការមិនធ្វើឲ្យប៉ះពាល់ដល់ការងារតាក់តែងសារណាបណ្តឹងសាទុក្ខ។ អង្គជំនុំជម្រះបានប្រកាសថានឹងចេញសេចក្តីសម្រេចមួយ នាពេលឆាប់ៗខាងមុខ។

៧. លោក ខៀវ សំផន និងមេធាវីរបស់គាត់ បានដឹងពីសេចក្តីសម្រេចនេះ ដែលបានចេញនៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ E320/1 (“សេចក្តីសម្រេច”) បន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤[6]។

៨. តាមរយៈឯកសារនេះ លោក ខៀវ សំផន និងមេធាវីរបស់គាត់ មានបំណងបញ្ជាក់សាជាថ្មីម្តងទៀត អំពីជម្រើសរបស់ខ្លួនក្នុងការមិនចូលរួមសវនាការលើសំណុំរឿង ០០២/០២ ដរាបណាខ្លួនមិនទាន់បញ្ចប់ការតាក់តែងសារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ពោលគឺ រហូតដល់ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ពីព្រោះថា នេះគឺជាកាលបរិច្ឆេទចុងក្រោយដែលបានកំណត់ដោយតុលាការកំពូល[7]។

៩. មេធាវីការពារក្តីជំទាស់ទាំងស្រុងទៅនឹងមតិ និងទឡ្ហីករណ៍ ដែលលើកឡើងក្នុងសេចក្តីសម្រេច។

## ១- “ការព្រមាន”

១០. នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះបញ្ជាក់ថា មេធាវីការពារក្តីលោក ខៀវ សំផន បាន

---

[6] សេចក្តីសម្រេចបន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **E320/1** (“សេចក្តីសម្រេច”)។

[7] សេចក្តីសម្រេចលើសំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រ សម្រាប់សារណាបណ្តឹងសាទុក្ខ និងសារណាតប ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **F9**។

ចូលរួមក្នុងកិច្ចប្រជុំរៀបចំសវនាការ *"ក្រោយពីទទួលការព្រមាន"*[8]។

១១. មេធាវីការពារក្តីសូមរំឭកដល់អង្គជំនុំជម្រះថា មេធាវីការពារក្តីម្ចាស់ការលើរបៀបរៀបចំការងារ និងរបៀបការពារផលប្រយោជន៍របស់កូនក្តីឱ្យបានប្រសើរបំផុត។ មេធាវីការពារក្តីយល់ឃើញថា អង្គជំនុំជម្រះមិនមែនជាអ្នកធានា ឬជាអ្នកគ្រប់គ្រងលើក្រមសីលធម៌របស់មេធាវីការពារក្តីនោះទេ ហើយក៏មិនអាចព្រមានដល់មេធាវីការពារក្តីបានឡើយ។ សូមរំឭកថា មេធាវីការពារក្តីបានបង្ហាញអំពីគោលជំហររបស់ខ្លួន នៅក្នុងសវនាការកាលពីថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ដោយបានជម្រាបជូនអង្គជំនុំថា ខ្លួននឹងអវត្តមានក្នុងសវនាការនានា នាពេលខាងមុខ។

១២. ដូច្នេះ អវត្តមាននាពេលនោះ មិនមែនជាការបង្កភាពរាំងស្ទះដល់កិច្ចដំណើរការនីតិវិធីនោះទេ គឺជាការពន្យល់ថា មេធាវីការពារក្តីនឹងមិនចូលរួមក្នុងសវនាការ ដែលរៀបចំ និងប្រព្រឹត្តទៅ ដោយប៉ះពាល់ដល់នីតិវិធីប្តឹងសាទុក្ខដ៏សំខាន់សម្រាប់លោក ខៀវ សំផន នោះឡើយ។ ការចូលរួមនោះមិនសូវមានសារៈសំខាន់នោះទេ ពីព្រោះវារំលោភលើសេចក្តីបង្គាប់ដ៏ច្បាស់លាស់របស់ជនជាប់ចោទ។ ក្នុងល័ក្ខខ័ណ្ឌបែបនេះហើយទើបមេធាវីការពារក្តីបានអវត្តមាន ក្នុងកិច្ចប្រជុំរៀបចំសវនាការ កាលពីថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ ដែលមានរបៀបវារៈពាក់ព័ន្ធតែសំណុំរឿង ០០២/០២ ដោយសារតែខ្លួនជាប់រវល់ក្នុងការតាក់តែងសារណាបណ្តឹងសាទុក្ខ។

១៣. ប្រសិនបើមេធាវីការពារបានបង្ហាញខ្លួន ក្នុងកិច្ចប្រជុំ នៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ក៏ព្រោះតែខ្លួនត្រូវពន្យល់ម្តងទៀតឱ្យបានច្បាស់អំពីគោលជំហរ ដែលអង្គជំនុំជម្រះទំនងជាមិនយល់។ ជាក់ស្តែង នៅក្នុងលិខិតព្រមាន នៅពេលនិយាយពាក់ព័ន្ធនឹងកិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ អង្គជំនុំជម្រះបានប្រកាសថា មេធាវី *"មិនមានវត្តមាន ដោយមិនផ្តល់ហេតុផលសមស្របសម្រាប់អវត្តមានរបស់ពួកគេ"*[9]។

១៤. នៅក្នុងកិច្ចប្រជុំកាលពីថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានពន្យល់ឱ្យអង្គជំនុំជម្រះ

---

[8] សេចក្តីសម្រេច **E320/1** កថាខណ្ឌ ១។

[9] ការព្រមានដល់មេធាវីការពារក្តី នួន ជា និង ខៀវ សំផន ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **E320** កថាខណ្ឌ ៤, កថាខណ្ឌ ៨។

យល់ថា ការមានៈចង់បង្ខំបើកសវនាការលើសំណុំរឿង ០០២/០២ ក្នុងពេលកំពុងរៀបចំបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០១ គឺជាការរំលោភលើសិទ្ធិជាមូលដ្ឋានរបស់លោក ខៀវ សំផន។ ក្នុងឱកាសនោះ មេធាវីការពារក្ដីក៏បានរំឭកផងដែរអំពីអត្ថបទជាមូលដ្ឋានពាក់ព័ន្ធនឹងក្រមសីលធម៌វិជ្ជាជីវៈ ដែលរារាំងមេធាវីមិនឲ្យធ្វើអំពើដែលខ្លួនយល់ឃើញថាផ្ទុយនឹងផលប្រយោជន៍របស់កូនក្ដី[10]។

## ២- ភាពធំធេងរបស់លោក ខៀវ សំផន សម្រាប់កិច្ចដំណើរការនីតិវិធីពីរក្នុងពេលដំណាលគ្នា

១៥. ក្នុងកថាខណ្ឌ ៤ នៃសេចក្ដីសម្រេច អង្គជំនុំជម្រះលើកឡើងថា៖
*"កិច្ចដំណើរការនីតិវិធីតាមផ្លូវច្បាប់ប្រឆាំងនឹងជនជាប់ចោទ ពាក់ព័ន្ធនឹងការជំនុំជម្រះក្ដីនៅអង្គជំនុំជម្រះសាលាដំបូងផង និងបណ្ដឹងសាទុក្ខផង។ ជនជាប់ចោទមិនមានលទ្ធភាពជ្រើសរើសរវាងកិច្ចដំណើរការនីតិវិធីណាមួយ ក្នុងចំណោមកិច្ចដំណើរការនីតិវិធីទាំងពីរនេះនោះទេ ពីព្រោះកិច្ចដំណើរការនីតិវិធីនីមួយៗសុទ្ធតែជាកាតព្វកិច្ច ទោះបីជាក្នុងរយៈពេលមួយមានកំណត់ក្ដី"*។

១៦. មេធាវីការពារក្ដីលោក ខៀវ សំផន សូមបញ្ជាក់ជូនអង្គជំនុំជម្រះថា បញ្ហាមិនមែននៅត្រង់ថាតើកិច្ចដំណើរការនីតិវិធី "មិនមែនជាកាតព្វកិច្ច" ឬជាកាតព្វកិច្ចនោះទេ គឺនៅត្រង់ថាតើ លោក ខៀវ សំផន និងមេធាវីរបស់គាត់ មានពេលធ្វើការលើកិច្ចដំណើរការនីតិវិធីពីរក្នុងពេលដំណាលគ្នា ដែរឬទេ និងថាតើការដាក់ល័ក្ខខ័ណ្ឌកំហិតបែបនេះរំលោភដល់សិទ្ធិរបស់លោក ខៀវ សំផន ក្នុងការទទួលបានពេលវេលាគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំការពារខ្លួន ដែរឬទេ។

១៧. មេធាវីការពារក្ដីចាំបាច់ត្រូវតែរំឭកថា ដូចអនុសញ្ញាអន្តរជាតិនានាស្ដីពីសិទ្ធិមនុស្សដែរ រដ្ឋធម្មនុញ្ញកម្ពុជា កិច្ចព្រមព្រៀង និងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ទទួលស្គាល់ថា ជនជាប់ចោទមានសិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំការពារខ្លួន[11]។ សិទ្ធិនេះត្រូវបាន

---

[10] ប្រតិចារឹកសវនាការ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **E1/244.1** ទំព័រ ៣៥ ដល់ទំព័រ ៣៧ ចន្លោះម៉ោង [11.08.07] ដល់ [11.15.58], ទំព័រ ៤០ ដល់ទំព័រ ៤១ ចន្លោះម៉ោង [11.23.40] ដល់ [11.29.24]។

[11] មាត្រា ១៤(៣)(ខ) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ៦ នៃអនុសញ្ញាអឺរ៉ុបស្ដីពីការការពារសិទ្ធិ និងសេរីភាពជាមូលដ្ឋាន, មាត្រា ៣១ និងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញកម្ពុជា"),

ទទួលស្គាល់ដោយតុលាការកំពូល ទុកដូចជា *“ការអនុវត្តសិទ្ធិឱ្យមានប្រសិទ្ធភាព និងមានអត្ថន័យក្នុងការប្តឹងសាទុក្ខ”*[12]។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការពិសេសក៏ទទួលស្គាល់សិទ្ធិនេះផងដែរ ហើយបានបន្ថែមថា *“អង្គជំនុំជម្រះសាលាដំបូងត្រូវជួយជ្រោមជ្រែងឱ្យអស់ពីលទ្ធភាព នៅពេលភាគីណាមួយស្នើសុំឱ្យជួយក្នុងការបង្ហាញរឿងក្តីរបស់ខ្លួន”*[13]។ ជាក់ស្តែង យោងតាមយុត្តិសាស្ត្រចំណាស់ និងនៅមានសុពលភាពរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ថៅក្រុមមានករណីយកិច្ចធានានូវការគោរពសិទ្ធិជាមូលដ្ឋាន និងធានា *“សិទ្ធិជាក់ស្តែង និងពិតប្រាកដ មិនមែនសិទ្ធិទ្រឹស្តី ឬសិទ្ធិស្រមើស្រមៃនោះទេ”*[14]។

១៨. ផ្ទុយទៅវិញ សេចក្តីសម្រេចមិនឆ្លើយតបទាល់តែសោះទៅនឹងកង្វល់ជាចម្បងទាំងនេះ។ សេចក្តីសម្រេចខំប្រឹងផ្អែកលើយុត្តិសាស្ត្រអន្តរជាតិមួយ (មិនជាប់ពាក់ព័ន្ធ) ខណៈដែលតាមការពិត គ្មានជនជាប់ចោទណាម្នាក់ នៅចំពោះមុខតុលាការអន្តរជាតិ ត្រូវបានរុញច្រានឱ្យធ្លាក់ក្នុងស្ថានភាពបែបនេះនោះទេ។ ស្ថានភាពបែបនេះកើតចេញយ៉ាងច្បាស់ក្រឡែតពីសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះក្នុងរឿងក្តីនេះ (សេចក្តីសម្រេចដែលរងនូវការជំទាស់)។

១៩. ម្យ៉ាងវិញទៀត នេះគឺជាមូលហេតុមួយក្នុងចំណោមមូលហេតុនានា ដែលតុលាការព្រហ្មទណ្ឌអន្តរជាតិជៀសវាងបំបែកសំណុំរឿងដែលមានទំហំធំធេងបែបនេះ។

២០. ច្បាស់ណាស់ថា ទាំងនៅក្នុងការបដិសេធសំណើសុំឱ្យពិចារណាឡើងវិញលើដីកាកំណត់កាលបរិច្ឆេទ ទាំងនៅក្នុងសេចក្តីសម្រេច អង្គជំនុំជម្រះមិនបាននិយាយទាល់តែសោះដល់យុត្តិសាស្ត្រ

---

មាត្រា ១៣(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (“កិច្ចព្រមព្រៀង”), មាត្រា ៣៥ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

[12] ឧទាហរណ៍៖ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E284/2/1/2** កថាខណ្ឌ ៦ និងកំណត់សម្គាល់ជើងទំព័រ ១២ និង ១៣។

[13] Nahimana *និងអ្នកឯទៀត ទល់នឹងរដ្ឋអាជ្ញា* រឿងក្តីលេខ ICTR-99-52-A សាលដីកា ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ២២០ និងកំណត់សម្គាល់ជើងទំព័រ ៥៣២ និង ៥៣៣។

[14] រឿងក្តី *Airey* ទល់នឹងប្រទេសអៀរឡង់ សំណើលេខ 6289/73 សាលដីកាលើអង្គសេចក្តី ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៧៩ កថាខណ្ឌ ២៤។

*Mladic* ដែលមេធាវីការពារក្ដីយកមកធ្វើជាមូលដ្ឋានបង្អែក[15]។ យុត្តិសាស្ត្រនេះស្ទើរតែដូចគ្នាទៅនឹងស្ថានភាពបច្ចុប្បន្ននេះ ពីព្រោះវាជាបញ្ហានៃការបំបែកកិច្ចដំណើរការនីតិវិធី។ ក៏ប៉ុន្តែ ខណៈដែលអង្គជំនុំជម្រះយល់ឃើញថាការប្រព្រឹត្តទៅក្នុងពេលដំណាលគ្នានៃនីតិវិធីពីរ គឺជាកាតព្វកិច្ច យុត្តិសាស្ត្រ *Mladic* យល់ឃើញថា ការបំបែកកិច្ចដំណើរការនីតិវិធីបង្កឲ្យមាន<u>ភាពប៉ះទង្គិចគ្នា</u>យ៉ាងពិតប្រាកដ រវាងកិច្ចដំណើរការនីតិវិធីពីរ៖

*៣១. អង្គជំនុំជម្រះយល់ឃើញថា ការបំបែក និងការដំណើរការជំនុំជម្រះក្ដីពីរ អាចបង្កព្យសនកម្មដល់ជនជាប់ចោទ ជាពិសេស<u>លទ្ធភាពក្នុងការចូលរួមដោយផ្ទាល់</u>ក្នុងការរៀបចំការពារខ្លួនសម្រាប់ការជំនុំជម្រះទីពីរ។ អង្គជំនុំជម្រះយល់ឃើញថា <u>ការចូលរួមក្នុងការត្រៀមលក្ខណៈមុនការជំនុំជម្រះនៃរឿងក្ដីមួយ ដោយចូលរួមក្នុងពេលដំណាលគ្នាទៅក្នុងដំណាក់កាលជំនុំជម្រះ ឬប៉ុងសាទុក្ខនៃរឿងក្ដីទីមួយ អាចធ្វើឲ្យជនជាប់ចោទរ៉ាប់រងបន្ទុកធ្ងន់ធ្ងរពេកយ៉ាងអយុត្តិធម៌ និងកម្រិតលទ្ធភាពរបស់ជនជាប់ចោទ ក្នុងការចូលរួមប្រកបដោយប្រសិទ្ធភាព ក្នុងរឿងក្ដីទីមួយ ឬទីពីរ</u>។ អង្គជំនុំជម្រះយល់ឃើញថា <u>ការបែងចែកពេលវេលា និងការយកចិត្តទុកដាក់ ដែលជនជាប់ចោទត្រូវការដើម្បីចូលរួមក្នុងការការពារក្ដីរបស់គាត់ ក្នុងរឿងក្ដីទាំងពីរ អាចធ្វើឲ្យការចូលរួមរបស់គាត់មិនសូវមានប្រសិទ្ធភាព និងតម្រូវជាចាំបាច់ឲ្យបន្ថយល្បឿនកិច្ចដំណើរការនីតិវិធីសម្រាប់រឿងក្ដីទាំងពីរ</u>។ ជាចុងក្រោយ អង្គជំនុំជម្រះយល់ឃើញថា ការពិចារណាជាក់ស្ដែងនៃរឿងក្ដីទាំងពីរ ដូចជា តម្រូវការក្នុងការជួល និងសម្របសម្រួលមេធាវីការពារក្ដីពីរក្រុម <u>ក៏នឹងបង្កភាពស្មុគស្មាញផងដែរដល់លទ្ធភាពរបស់ជនជាប់ចោទ ក្នុងការចូលរួមក្នុងការរៀបចំការពារខ្លួន ក្នុងរឿងក្ដីនីមួយៗ ហើយរឹតតែពន្យឺតកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីដែលបានបំបែក</u>។*

*៣២. ខណៈពេលដែលអង្គជំនុំជម្រះទទួលស្គាល់សារណារបស់អយ្យការថា ការកំណត់ពេលវេលា*

---

[15] សំណើជាបន្ទាន់សុំឲ្យពិចារណាឡើងវិញ លើដីកាកំណត់កាលបរិច្ឆេទ សម្រាប់សវនាការលើអង្គសេចក្ដី ក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **E314/5/1** កថាខណ្ឌ ១៣, ប្រតិចារឹកសវនាការ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **E1/244.1** ទំព័រ ១៨ ប្រហែលម៉ោង [09.34.13], *រដ្ឋអាជ្ញា ទល់នឹង* *Ratko Mladic* រឿងក្ដីលេខ IT-09-92-PT សេចក្ដីសម្រេចលើសំណើរួមរបស់រដ្ឋអាជ្ញា សុំបំបែកដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដំណើរការជំនុំជម្រះក្ដីដាច់ដោយឡែកពីគ្នា និងកែប្រែដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១១ ("យុត្តិសាស្ត្រ *Mladic*") កថាខណ្ឌ ៣១ និង កថាខណ្ឌ ៣២។

*នៃការជំនុំជម្រះទីពីរអាចត្រូវបានពែលព្រែ ដើម្បីការពារសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាន ពេលវេលាគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួន អង្គជំនុំជម្រះយល់ឃើញថា ទទ្បីករណ៍នៃការពន្យារ ពេលជំនុំជម្រះទីពីរ ដោយផ្អែកលើករណីនៃការជំនុំជម្រះទីមួយ អាចបង្កព្យសនកម្មស្មើគ្មាដល់សិទ្ធិ របស់ជនជាប់ចោទក្នុងការជំនុំជម្រះ ដោយគ្មានពន្យារពេល។ មេធាវីការពារក្តីបញ្ជាក់យ៉ាងច្បាស់ នៅក្នុងសារណារបស់ខ្លួនថា ជនជាប់ចោទត្រៀមខ្លួនដើម្បីឆ្លើយតបទៅនឹងបទចោទទាំងមូល ដែល គាត់កំពុងតែប្រឈម។ <u>ក្នុងករណីដំណើរការបណ្តឹងសាទុក្ខយូរ ការពន្យារជាសក្តានុពលនៃការជំនុំ ជម្រះទីពីរនេះអាចនឹងមានកម្រិតខ្ពស់</u>។ សិទ្ធិក្នុងការមានពេលវេលាគ្រប់គ្រាន់ ដើម្បីរៀបចំការពារ ខ្លួនឱ្យបានសមស្រប និងសិទ្ធិក្នុងការទទួលបានការជំនុំជម្រះ ដោយគ្មានពន្យារពេល គឺជាសិទ្ធិ រដ្ឋមានរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះមិនយល់ស្របទេថាសិទ្ធិទាំងនេះគួរតែមានការប៉ះទង្គិច គ្នានោះទេ ប្រសិនបើអាចជៀសវាងបាន ហើយអង្គជំនុំជម្រះយល់ឃើញថា ការបំបែក និងការ ដំណើរការជំនុំជម្រះក្តីពីរ អាចបង្កឱ្យមានការប៉ះទង្គិច ដែលមិនមាន នាពេលបច្ចុប្បន្ននេះ។*

២១. ដូចដែលមេធាវីការពារក្តីបានបញ្ជាក់ជាច្រើនលើកច្រើនសាររួចមកហើយ ការវិភាគធ្វើឡើងដោយ ចៅក្រមនៅក្នុងរឿងក្តី *Mladic* គឺកាន់តែបង្ហាញឱ្យឃើញពីភាពពាក់ព័ន្ធនៅពេលដែលជនជាប់ ចោទ មានអាយុ ៨៣ ឆ្នាំ ជាក់ស្តែងដូចជានៅក្នុងករណីរបស់ លោក ខៀវ សំផន។

២២. ដូច្នេះវាពិតជាមិនអាចប្រកែកបានឡើយដែលថា លោក ខៀវ សំផន ដែលកំពុងត្រូវបានដាក់ឱ្យ ស្ថិតនៅក្នុងស្ថានភាពនៃគំនាបពីរដំណាលគ្នាបែបនេះ មានហេតុផលក្នុងការសម្រេចជ្រើសយកការ ផ្តោតកម្លាំងរបស់គាត់លើការធ្វើបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿង ០០២/០១ ជាពិសេសនៅពេល ដែលរឿងក្តីនេះត្រូវបានចាត់ទុកយ៉ាងហោចណាស់ដោយអង្គជំនុំជម្រះថាជា "មូលដ្ឋាន" នៃរឿងក្តី បន្ទាប់[16]។

## ៣- <u>យុត្តិសាស្ត្រយោងដោយអង្គជំនុំជម្រះនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន គឺមិនមានភាពពាក់ព័ន្ធ</u>

២៣. នៅក្នុងកថាខណ្ឌទី៤ ដដែល នៃសេចក្តីសម្រេច អង្គជំនុំជម្រះបានអះអាងថា៖

[16] ឧទាហរណ៍ សូមមើលឯកសារថ្មីៗនេះ៖ សេចក្តីបញ្ជាក់បំភ្លឺអំពីផលវិបាកនៃការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **E318** កថាខណ្ឌ ១។

*"[...] ការលើកឡើងថា សិទ្ធិរបស់ជនជាប់ចោទដើម្បីចូលរួមឲ្យបានពេញលេញនៅក្នុងការការពារខ្លួនត្រូវបានរំលោភ ដោយសារជនជាប់ចោទមិនអាចចំណាយពេលវេលាទាំងអស់របស់គាត់ ដើម្បីបំពេញការងារទៅលើបណ្តឹងសាទុក្ខនោះ គឺជាការលើកឡើងផ្ទុយទៅនឹងយុត្តិសាស្ត្រអន្តរជាតិដែលពាក់ព័ន្ធ"*។

២៤. អង្គជំនុំជម្រះបានបង្ហាញយុត្តិសាស្ត្រចំនួនពីររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលត្រូវបានសន្មតថាបានបដិសេធពីសុពលភាពនៃទឡ្ហីករណ៍របស់មេធាវីការពារក្តី (រឿងក្តី *Boskoski* ឆ្នាំ ២០០៨ និងរឿងក្តី *Popovic* ឆ្នាំ ២០១០)[17]។

២៥. ដើម្បីយល់ឲ្យបានច្បាស់ពីយុត្តិសាស្ត្រទាំងពីរនេះ និងភាពមិនអាចអនុវត្តបានរបស់វាទៅលើស្ថានភាពបច្ចុប្បន្ននេះ ជាបឋម គេត្រូវបញ្ជាក់ឲ្យច្បាស់ថាវាជាស្ថានភាពដែលនៅក្នុងនោះ ជនជាប់ចោទស្នើសុំរយៈពេលធ្វើបណ្តឹងសាទុក្ខ ដោយត្រូវរង់ចាំទទួលបានការបកប្រែសាលក្រមដែលរងបណ្តឹងសាទុក្ខ ជាភាសាដែលជនជាប់ចោទអាចយល់បាន។ នៅក្នុងយុត្តិសាស្ត្រទាំងពីរនេះ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធផ្តល់ជូនពេលវេលាដែលស្នើសុំ ដោយពិចារណាឃើញថា៖

> "*នៅពេលដែលប្តឹងសាទុក្ខ បន្ទុកសំខាន់គឺស្ថិតនៅលើមេធាវីក្នុងការរៀបចំសារណា ពីព្រោះថាគាត់មានជំនាញផ្នែកច្បាប់ដើម្បីផ្តល់ប្រឹក្សាយោបល់ជូនអ្នកប្តឹងសាទុក្ខ ថាតើអាចមានអត្ថិភាពកំហុសឆ្គងអង្គច្បាប់ និងអង្គហេតុណាមួយឬអត់*"[18]។

២៦. នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះបានប្រើប្រាស់យុត្តិសាស្ត្រទាំងនេះដើម្បីគាំទ្រអំណះអំណាងរបស់ខ្លួន ដែលលើកឡើងថាបន្ទុកនៃការរៀបចំបណ្តឹងសាទុក្ខត្រូវធ្លាក់ជាពិសេសទៅលើ

---

[17] សេចក្តីសម្រេច **E320/1** កថាខណ្ឌ ៤ កំណត់សម្គាល់ជើងទំព័រ ៣៖ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Boskoski *និង* Tarculovski រឿងក្តីលេខ IT-04-82-A *សេចក្តីសម្រេចលើសំណើរបស់* Johan Tarculovski *សុំពន្យារពេលវេលាដើម្បីដាក់សារណាបណ្តឹងសាទុក្ខ* ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៨ ("យុត្តិសាស្ត្រ *Boskoski* "), រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Popovic *និងអ្នកឯទៀត* រឿងក្តីលេខ IT-05-00-A *សេចក្តីសម្រេចលើសំណើសុំពន្យារពេលវេលា និងចំនួនទំព័រលើសការកំណត់* ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១០ ("យុត្តិសាស្ត្រ *Popovic* ")។

[18] យុត្តិសាស្ត្រ *Boskoski* ទំព័រ ២ និងយុត្តិសាស្ត្រ *Popovic* ទំព័រ ៤។

មេធាវីការពារក្ដី ជាហេតុធ្វើឱ្យការចូលរួមរបស់លោក ខៀវ សំផន មិនសូវមានសារៈសំខាន់ អាស្រ័យហេតុនេះ ជនជាប់ចោទអាចធ្វើអ្វីផ្សេងក្រៅពីនេះ។

២៧. តាមការពិត យុត្តិសាស្ត្រទាំងនេះមិនសូវពាក់ព័ន្ធនឹងស្ថានភាពបច្ចុប្បន្នដែលមើលទៅមានលក្ខណៈដូចគ្នាជាងទៅនឹងស្ថានភាពដែលបានលើកឡើងរួចមកហើយនៅក្នុងយុត្តិសាស្ត្រក្នុងរឿងក្ដី *Mladic* ដែលបញ្ហាពិតប្រាកដស្ថិតនៅលើការបំបែកកិច្ចដំណើរការនីតិវិធី។

២៨. លើសពីនេះទៅទៀត យុត្តិសាស្ត្រទាំងអស់នេះមិនសូវជាមានភាពពាក់ព័ន្ធនោះទេ ព្រោះថាអង្គជំនុំជម្រះដដែលតែមួយ (អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការពិសេស) បានចេញសេចក្ដីសម្រេចផ្សេងៗទៀតដែលមានចំនួនច្រើនជាង ហើយដែលសេចក្ដីសម្រេចមួយចំនួនត្រូវបានចេញនាពេលថ្មីៗនេះ មកបន្ថយឥទ្ធិពល និងថែមទាំងបដិសេធនូវអំណះអំណាងរបស់អង្គជំនុំជម្រះ ដែលយើងនឹងមើលឃើញនៅក្នុងផ្នែកបន្តបន្ទាប់ទៀត (ផ្នែកទី ៤ និងទី ៥)។

២៩. ម្យ៉ាងវិញទៀត យុត្តិសាស្ត្រទាំងពីរដែលយោងដោយអង្គជំនុំជម្រះ ត្រូវបានចេញនៅក្នុងបរិបទមួយដែលខុសគ្នាទាំងស្រុងពីបរិបទរបស់ អ.វ.ត.ក ហើយការអាននូវសេចក្ដីសម្រេចទាំងនេះអាចឱ្យគេយល់បានថា គឺធាតុផ្សំមួយក្នុងចំណោមនៃធាតុផ្សំបរិបទទាំងនោះ ត្រូវបានយកមកប្រើជាមូលដ្ឋាននៃសេចក្ដីសម្រេចទាំងពីរនេះ។

៣០. ដូច្នេះ នៅក្នុងយុត្តិសាស្ត្ររឿងក្ដី *Boskoski* និង *Popovic* វាបានបញ្ជាក់យ៉ាងច្បាស់ពីលទ្ធភាពក្នុងការកែប្រែសេចក្ដីជូនដំណឹង និង/ឬ សារណាបណ្ដឹងសាទុក្ខ បន្ទាប់ពីការដាក់នូវឯកសារទាំងអស់នោះ ដោយអនុលោមទៅតាមច្បាប់ជាធរមាន។ ដូច្នេះ វាបានរំឭកយ៉ាងច្បាស់ថាម្ចាស់បណ្ដឹងសាទុក្ខនៅតែអាចស្នើសុំការអនុញ្ញាតធ្វើការកែប្រែ ឬបំពេញបន្ថែមសារណាបណ្ដឹងសាទុក្ខរបស់ខ្លួនក្រោយពីបានអានសាលក្រមបកប្រែជាភាសារបស់ពួកគេ និងបន្ទាប់ពីបានពិភាក្សាជាមួយមេធាវីរបស់ខ្លួន[19]។

[19] យុត្តិសាស្ត្រ *Boskoski* ទំព័រ ២ ដល់ទំព័រ ៣, យុត្តិសាស្ត្រ *Popovic* ទំព័រ ៤ ដល់ទំព័រ ៥។

៣១. យ៉ាងណាមិញ អង្គជំនុំជម្រះបានដឹងយ៉ាងច្បាស់ថាលទ្ធភាពក្នុងការស្នើសុំអនុញ្ញាតកែប្រែសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ និង/ឬ សារណាបណ្ដឹងសាទុក្ខ ពុំមាននោះទេនៅ អ.វ.ត.ក។

៣២. ដូច្នេះ យុត្តិសាស្ត្រទាំងពីរនេះ ដែលខុសគ្នាទៅនឹងយុត្តិសាស្ត្រក្នុងរឿងក្ដី *Mladic* គឺមិនមានភាពពាក់ព័ន្ធ និងពិតជាមិនអាចធ្វើឲ្យលោក ខៀវ សំផន និងមេធាវីរបស់គាត់ ផ្ដោតការយកចិត្តទុកដាក់លើការងារបណ្ដឹងសាទុក្ខដ៏មានសារៈសំខាន់ ដោយទុកឲ្យសវនាការក្នុងសំណុំរឿងទីពីរ ឬដែលជារឿងក្ដីបន្ទាប់បន្សំមករំខាននោះទេ។

## ៤- <u>យុត្តិសាស្ត្រផ្សេងៗទៀតរបស់អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការពិសេសនានា</u>

៣៣. ដូចដែលបានបញ្ជាក់ពីខាងដើម គឺវានៅមានសេចក្ដីសម្រេចផ្សេងៗទៀតរបស់អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលឆ្លើយតបទៅនឹងសំណើសុំពេលវេលារបស់ក្រុមមេធាវីការពារក្ដីសម្រាប់ការដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ និងការដាក់សារណាបណ្ដឹងសាទុក្ខ។

៣៤. អ្វីដែលគួរឲ្យចាប់អារម្មណ៍ក្នុងការកត់សម្គាល់នោះគឺថា នៅក្នុងករណីជាច្រើន ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលបដិសេធពន្យាររយៈពេលកំណត់សម្រាប់ការដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ក្រោមហេតុផលនៃការពុំមានការបកប្រែសាលក្រមជាភាសាដែលជនជាប់ចោទអាចយល់បាន អង្គជំនុំជម្រះតុលាការកំពូលនឹងយល់ព្រមពន្យាររយៈពេលកំណត់នេះដើម្បីការងាររៀបចំសារណាបណ្ដឹងសាទុក្ខ។

៣៥. ដូចគ្នាទៅនឹងយុត្តិសាស្ត្រក្នុងរឿងក្ដី *Boskoski* ឆ្នាំ ២០០៨ និងរឿងក្ដី *Popovic* ឆ្នាំ ២០១០ សេចក្ដីសម្រេចទាំងនេះផ្អែកលើការណ៍ដែលថា នៅក្នុងដំណើរការនីតិវិធីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី មេធាវីដែលបានធ្វើការជាមួយកូនក្ដីរបស់ខ្លួន តែងតែមានលទ្ធភាពស្នើសុំកែប្រែមូលដ្ឋាននៃបណ្ដឹងសាទុក្ខដែលមាននៅក្នុងសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ។

៣៦. នៅទីនេះ អង្គជំនុំជម្រះតុលាការកំពូល ដែលបានផ្ដល់រយៈពេលបន្ថែមសម្រាប់ការសរសេរសារណាបណ្ដឹងសាទុក្ខ (និងសម្រាប់ការឆ្លើយតបទៅនឹងបណ្ដឹងសាទុក្ខរបស់រដ្ឋអាជ្ញា ក្នុងករណីផ្សេងទៀត) បានរំឭកចំនុចមួយថាជនជាប់ចោទត្រូវមានលទ្ធភាពសន្ទនាជាមួយមេធាវីរបស់ខ្លួន ("*consult with*") និងដាក់ចេញជា*អនុសាសន៍ចាំបាច់ និងឯកភាពជាស្ថាពរលើសារណាបណ្ដឹងសាទុក្ខរបស់ខ្លួន*' ជាក់ស្ដែងដូចជានៅក្នុងករណីយុត្តិសាស្ត្រទាំងប្រាំមួយក្នុងរឿងក្ដី *Gatete, Hategekimana* និង *Kanyarukiga* ឆ្នាំ ២០១១ ឬក៏នៅក្នុងរឿងក្ដី *Nizeyimana, Ndahimana* និង *Karemera* ឆ្នាំ ២០១២[20]។

៣៧. លោក ខៀវ សំផន និងមេធាវីរបស់គាត់ កំពុងស្ថិតនៅច្បាស់ណាស់ក្នុងដំណាក់កាលនៃការរៀបចំសារណាបណ្ដឹងសាទុក្ខ ក្នុងសំណុំរឿងមួយដែលមានលក្ខណៈស្មុគស្មាញបំផុត។ ម្យ៉ាងវិញទៀត វាគឺជាចំណុចសំខាន់មួយនៃសំអាងហេតុរបស់តុលាការកំពូលក្នុងការផ្ដល់ពេលវេលាកំណត់បន្ថែមសម្រាប់ការដាក់សារណាបណ្ដឹងសាទុក្ខ។ តុលាការកំពូលបានលើកឡើងដូច្នេះថា៖
*"[...] អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា រយៈពេល ៦០ ថ្ងៃ ដែលមានកំណត់នៅក្នុងវិធាន ១០៧ ៤) នៃវិធានផ្ទៃក្នុងនោះ មិនគ្រប់គ្រាន់ឡើយសម្រាប់ នួន ជា និង ខៀវ សំផន ក្នុងការ*

---

[20] រឿងក្ដី *Kanyarukiga ទល់នឹង រដ្ឋអាជ្ញា* រឿងក្ដីលេខ ICTR-02-78-*A សេចក្ដីសម្រេចលើសំណើរបស់ Gaspard Kanyarukiga សុំពន្យាររយៈពេលដាក់សារណារបស់ម្ចាស់បណ្ដឹងសាទុក្ខ និងសុំពន្លឿនការបកប្រែសាលក្រមជាភាសា* Kinyarwanda ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១១ ទំព័រ ៣, រឿងក្ដី *Hategekimana ទល់នឹង រដ្ឋអាជ្ញា* រឿងក្ដីលេខ ICTR-00-55B-A សេចក្ដីសម្រេចលើសំណើលើកទីពីររបស់ Ildéphonse Hategekimana សុំឱ្យពន្យារពេលវេលាកំណត់ក្នុងការដាក់សារណាបណ្ដឹងសាទុក្ខ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១១ កថាខណ្ឌ ៦ និង ៧, រឿងក្ដី *Gatete ទល់នឹង រដ្ឋអាជ្ញា* រឿងក្ដីលេខ ICTR-00-61-A *សេចក្ដីសម្រេចលើការពន្យារពេលវេលាកំណត់* ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១១ កថាខណ្ឌ ៦ ដល់កថាខណ្ឌ ៨, រឿងក្ដី *Karemera និងអ្នកឯទៀត ទល់នឹង រដ្ឋអាជ្ញា* រឿងក្ដីលេខ ICTR-98-44-A *សេចក្ដីសម្រេចលើសំណើសុំពន្យារពេលវេលាកំណត់សម្រាប់ការដាក់សារណាបណ្ដឹងសាទុក្ខ* ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៧, រឿងក្ដី *Ndahimana ទល់នឹង រដ្ឋអាជ្ញា* រឿងក្ដីលេខ ICTR-01-68-A *សេចក្ដីសម្រេចលើសំណើរបស់ Grégoire Ndahimana សុំពន្យារពេលវេលាកំណត់ក្នុងការដាក់សារណាបណ្ដឹងសាទុក្ខ និងសារណាតបរបស់ខ្លួន* ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១២ ទំព័រ ២, រឿងក្ដី *Nizeyimana ទល់នឹង រដ្ឋអាជ្ញា* រឿងក្ដីលេខ ICTR-00-55C-A *សេចក្ដីសម្រេចលើសំណើរបស់ Ildéphonse Nizeyimana សុំពន្យារពេលវេលាកំណត់ក្នុងការដាក់សារណាបណ្ដឹងសាទុក្ខ* ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ ទំព័រ ២។

*ប្តឹងសាទុក្ខប្រកបដោយអត្ថន័យប្រឆាំងនឹងសាលក្រមដែលមានទំហំធំ និងមានភាពស្មុគស្មាញដូច សំណុំរឿងបច្ចុប្បន្ននេះ”*[21]។

៣៨. លើសពីនេះទៅទៀត ការអានសេចក្តីសម្រេចទាំងអស់នេះរបស់អង្គជំនុំជម្រះតុលាការកំពូល នៃ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា អាចឲ្យគេកត់សម្គាល់ថាចំពោះតុលាការ មួយនេះ ការរៀបចំបណ្តឹងសាទុក្ខត្រូវធ្វើឡើងក្នុងគ្រប់ដំណាក់កាលទាំងអស់ ដោយមានការ ពិគ្រោះយោបល់ជាមួយនឹងកូនក្តី[22]។ ចៅក្រមតុលាការកំពូល យល់ឃើញថាអន្តរាគមន៍របស់កូនក្តី សំខាន់ណាស់នៅក្នុងដំណាក់កាលរៀបចំសារណាបណ្តឹងសាទុក្ខ ដែលការយល់ឃើញនេះពិតជា មានលក្ខណៈសមហេតុផល ព្រោះថាទឡ្ហីករណ៍ទាំងឡាយនឹងត្រូវលើកមកបង្ហាញនៅក្នុងសារណា នោះ។

៣៩. ដូច្នេះ ការសិក្សាយុត្តិសាស្ត្រនេះបង្ហាញឲ្យឃើញពីកម្រិតអសុពលភាពនៃទឡ្ហីករណ៍ដែលត្រូវបាន លើកឡើងនៅចុងកថាខណ្ឌទី ៤ នៃសេចក្តីសម្រេចដែលបានព្យាយាមទាញយកហេតុផលពីការដែល ថាសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន ត្រូវបានដាក់រួចមកហើយ។

## ៥- យុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

៤០. គេក៏អាចស្នើឲ្យអង្គជំនុំជម្រះមើលសេចក្តីសម្រេចក្នុងរឿងក្តី *Lubanga* កាលពីឆ្នាំ ២០១១ ពាក់ព័ន្ធ នឹងបញ្ហាមួយចំនួននៃការបកប្រែភាសា ដែលជាចំណុចចាប់ផ្តើមនៃរយៈពេលកំណត់នៃការធ្វើ បណ្តឹងសាទុក្ខ៖

“*វិធានការការពារអប្បបរមាមួយចំនួនគឺចាំបាច់ត្រូវមានដើម្បីធានាថា ជនជាប់ចោទ និងមេធាវីរបស់ គាត់មានលទ្ធភាពគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំសម្រាប់ដំណាក់កាលបន្ទាប់ប្រសិនបើជនជាប់ចោទ ត្រូវបានផ្តន្ទាទោស(...)។ ប្រសិនបើ [ជនជាប់ចោទ] ត្រូវបានផ្តន្ទាទោស គាត់នឹងត្រូវការរៀបចំ*

---

[21] *សេចក្តីសម្រេចលើសំណើសុំពន្យាររយៈពេលកំណត់ និងបន្ថែមចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខ និងសារណាតប* ចុះ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **F9** កថាខណ្ឌ ១៣ និង ១៨។

[22] សូមមើលកំណត់សម្គាល់ជើងទំព័រ ២០ ខាងលើ៖ សេចក្តីសម្រេចក្នុងរឿងក្តី *Kanyarukiga* ទំព័រ ៣, សេចក្តីសម្រេចក្នុង រឿងក្តី *Hategekimana* កថាខណ្ឌ ៦, សេចក្តីសម្រេចក្នុងរឿងក្តី *Karemera* កថាខណ្ឌ ១១។

*សម្រាប់ដំណាក់កាលប្តឹងសាទុក្ខនៅក្នុងរឿងក្តី(...)។ នៅក្នុងការជំនុំជម្រះក្តីនេះ ទោះបីជាសេចក្តីសន្និដ្ឋានរួមមានខ្លឹមសារយ៉ាងណាក៏ដោយ ក៏សាលក្រមនឹងមានច្រើនរយទំព័រ ហើយក៏ពាក់ព័ន្ធនឹងការពិចារណាលម្អិតទៅលើបញ្ហាអង្គច្បាប់ និងអង្គហេតុស្មុគស្មាញយ៉ាងច្រើន។ អង្គជំនុំជម្រះយល់ឃើញថា វានឹងមិនយុត្តិធម៌ទេចំពោះជនជាប់ចោទ(...)ដែលតម្រូវឲ្យជនជាប់ចោទ ត្រៀមរៀបចំសម្រាប់ដំណាក់កាលពិសេសនេះនៅក្នុងកិច្ចដំណើរការនីតិវិធីនៅពេលដែលជាក់ស្តែង គាត់មិនអាចអានសាលក្រមជាភាសាអង់គ្លេសបាន*"[23]។

៤១. ជាការពិតណាស់ សេចក្តីសម្រេចនេះលើកឡើងពីស្ថានភាពមួយដែលខុសគ្នាទៅនឹងស្ថានភាពនាពេលបច្ចុប្បន្ន ប៉ុន្តែយើងត្រូវកត់សម្គាល់ថាតុលាការព្រហ្មទណ្ឌអន្តរជាតិពុំបានបែងចែកពីភាពខុសគ្នារវាងកូនក្តី និងមេធាវី ឬរវាងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណាបណ្តឹងសាទុក្ខនោះទេ។ បញ្ហាកើតមានជាពិសេសចំពោះជនជាប់ចោទ និងសិទ្ធិរបស់គាត់។ យ៉ាងណាក៏ដោយ វាទំនងជាចាំបាច់ក្នុងការរំឭកឡើងវិញពីចំណុចនេះ។

## ៦- "ការចូលរួមឲ្យបានពេញលេញ"

៤២. នៅទីបញ្ចប់ កថាខណ្ឌទី ៥ នៃសេចក្តីសម្រេចចែងថា៖

> "*អង្គជំនុំជម្រះយល់ឃើញថា សិទ្ធិរបស់ជនជាប់ចោទនៅក្នុងការចូលរួមនៅក្នុងការការពារខ្លួនចំពោះការប្តឹងសាទុក្ខ ត្រូវបានគោរពតាមរយៈការចូលរួមយ៉ាងពេញលេញពីសំណាក់មេធាវីការពារក្តីរបស់គាត់ ដោយមានការគាំទ្រពីជនជាប់ចោទ។ អាស្រ័យហេតុនេះ ការពាក់ព័ន្ធរបស់ ខៀវ សំផន នៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ គឺមិនមានមូលដ្ឋានផ្លូវច្បាប់រឹងមាំសម្រាប់ឲ្យជនជាប់ចោទ ឬមេធាវីការពារក្តីរបស់គាត់ មិនចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះលើសំណុំរឿង ០០២/០២ នេះទេ*"។

---

[23] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Thomas Lubanga Dyilo* រឿងក្តីលេខ ICC-01/04-01/06 *សេចក្តីសម្រេចលើការបកស្រាយសេចក្តីសម្រេចផ្អែកតាមវិធាន ៧៤ និងបញ្ហានីតិវិធីពាក់ព័ន្ធនានា* ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ កថាខណ្ឌ ២១ ដល់កថាខណ្ឌ ២៤ (ដោយយោងទៅសេចក្តីសម្រេចមួយលើរឿងដូចគ្នា ដែលចេញដោយចៅក្រមផ្សេងៗទៀតនៅក្នុងរឿងក្តី *Bemba* ឆ្នាំ ២០១០ កថាខណ្ឌ ២៤)។

៤៣. ដូច្នេះ មេធាវីការពារក្តីសុំការអនុញ្ញាតរំឭកអង្គជំនុំជម្រះថា មេធាវីការពារក្តីមិនអាច*"ចូលរួមឲ្យបានពេញលេញ"*ក្នុងដំណើរការនីតិវិធីបណ្តឹងសាទុក្ខនោះទេ ប្រសិនបើនៅពេលដំណាលគ្នា ខ្លួនត្រូវរៀបចំ ចូលរួម និងមានវត្តមាននៅក្នុងសវនាការជំនុំជម្រះលើសំណុំរឿង ០០២/០២។

៤៤. ម្យ៉ាងវិញទៀត តាមរយៈការគំរាមដាក់ទណ្ឌកម្ម[24] លើលោក ខៀវ សំផន និងមេធាវីរបស់គាត់ ដើម្បីព្យាយាមបង្ខំពួកគាត់ឲ្យចូលរួមក្នុងសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះមិនត្រឹមតែបង្អាក់លោក ខៀវ សំផន ក្នុងការ*"ចូលរួមឲ្យបានពេញលេញ"*ក្នុងការរៀបចំបណ្តឹងសាទុក្ខរបស់គាត់ប៉ុណ្ណោះទេ ប៉ុន្តែអង្គជំនុំជម្រះថែមទាំងបានបំបាត់ចោលនូវអត្ថប្រយោជន៍លើពេលវេលាបន្ថែមដែលបានសម្រេចផ្តល់ដោយអង្គជំនុំជម្រះតុលាការកំពូល។ អង្គជំនុំជម្រះបានធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ លោក ខៀវ សំផន ក្នុងការទទួលបានពេលវេលាចាំបាច់ក្នុងការការពារខ្លួន ក្នុងក្របខណ្ឌនៃការធ្វើបណ្តឹងសាទុក្ខ ដែលជាជម្រើសចុងក្រោយរបស់គាត់តែមួយគត់ប្រឆាំងនឹងការផ្តន្ទាទោសរូបគាត់ឲ្យជាប់ពន្ធនាគារអស់មួយជីវិត។

៤៥. គ្មានតុលាការអន្តរជាតិ ឬតុលាការអន្តរជាតូបនីយកម្មណាមួយ មុនអង្គជំនុំជម្រះសាលាដំបូង របស់ អ.វ.ត.ក បានធ្វើសេចក្តីសម្រេចដែលប៉ះពាល់ដល់សិទ្ធិការពារខ្លួនរបស់ជនជាប់ចោទដូច្នេះនោះទេ។ មេធាវីការពារក្តីមិនអាចរួមចំណែករំលោភសិទ្ធិដែលសំខាន់ៗជាងគេទាំងឡាយរបស់ លោក ខៀវ សំផន ដោយតុលាការមួយដែលត្រូវធ្វើជាគំរូសម្រាប់សហគមន៍អន្តរជាតិ តាមរយៈការចូលរួមមិនពេញលេញ និងបង្ខំនោះទេ។

## ផ្អែកតាមសំអាងហេតុខាងលើនេះ

៤៦. លោក ខៀវ សំផន សូមជម្រាបអង្គជំនុំជម្រះ និងភាគីទាំងអស់ឲ្យបានជ្រាបថា ជំហររបស់គាត់នៅរក្សាដដែល ហើយមេធាវីរបស់គាត់នឹងមិនចូលរួមសវនាការជំនុំជម្រះលើសំណុំរឿង០០២/០២ នៅមុនការបញ្ចប់ការសរសេរសារណាបណ្តឹងសាទុក្ខរបស់គាត់នោះទេ។

[24] សេចក្តីសម្រេច **E320/1** កថាខណ្ឌ ១១។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន | រាជធានីភ្នំពេញ | |
| | មេធាវី Anta GUISSÉ | ទីក្រុងប៉ារីស | |
| | មេធាវី Arthur VERCKEN | ទីក្រុងប៉ារីស | |